**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ**

**THE STUDENT MOVEMENT FOR DEMOCRACY**

លេខ ០០២/២១ ច.ន.ប្រ.

# របាយការណ៍សង្ខេប

# បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០

## ១. ប្រវត្តិ

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ (The Student Movement For Democracy "SMD")** ត្រូវបានបង្កើតឡើងលើកដំបូងនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ នៅកម្ពុជា ហើយត្រូវបានរៀបចំឡើងវិញ នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២០ នៅរដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ដោយអតីតស្ថាបនិកនៃចលនានិស្សិត និងក្រុមបញ្ញវន្ត ជាមួយនឹងទស្សនវិស័យ «**ជម្រុញកម្ពុជាទៅកាន់លទ្ធិប្រជាធិបតេយ្យ យុត្តិធម៌ ឯកភាពជាតិ អធិបតេយ្យ និងបូរណភាពទឹកដីពេញលេញ**» ។

## ២. សកម្មភាពការងារ ២០២០

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ចូលរួមតស៊ូមតិថ្នាក់ជាតិ និងអន្តរជាតិ លើ**ការលើកកម្ពស់សិទ្ធិមនុស្ស ប្រជាធិបតេយ្យ កិច្ចការព្រំដែន និងដំណោះស្រាយនយោបាយ** នៅប្រទេសកម្ពុជា ។

**ក). អំពីបញ្ហាព្រំដែន ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** បានធ្វើប្រតិបត្តិការ ដូចខាងក្រោម ៖

- ផ្ញើលិខិតជាផ្លូវការទៅក្រសួងការបរទេស និងសមាជិកសភាអាមេរិក ស្តីអំពីការរំលោភលើច្បាប់សមុទ្រឆ្នាំ១៩៨២ ពីសំណាក់វៀតណាមមកលើប្រទេសកម្ពុជា ពាក់ព័ន្ធកោះត្រល់ និងចង្កោមកោះក្រចកសេះ។

- ផ្ញើលិខិតផ្លូវការជូននាយករដ្ឋមន្ត្រីនៃប្រទេសវៀតណាម ឲ្យរដ្ឋាភិបាលវៀតណាមត្រូវតែគោរព និងអនុវត្តតាមច្បាប់អន្តរជាតិ ជាដាច់ខាត ។

- ធ្វើការងារយ៉ាងសកម្មទាំងផ្នែកបច្ចេកទេស ច្បាប់ និងការទូត ជំរុញនិងទាមទារឲ្យប្រទេសវៀតណាមបញ្ឈប់រាល់គម្រោង និងផែនការអាជីវកម្ម ពាណិជ្ជកម្ម ព្រមទាំងការសាងសង់នានា នៅលើកោះត្រល់ និង ចង្កោមកោះក្រចកសេះ ដែលនៅតែជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ដោយយោងតាមសារាចររបស់អគ្គទេសាភិបាលបារាំង លោក **Brévié** ឆ្នាំ១៩៣៩, អនុសញ្ញាអន្តរជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២, កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញរបស់កម្ពុជា ឆ្នាំ១៩៩៣ ។

- ទាមទាមឲ្យរដ្ឋាភិបាលលោក **ហ៊ុន សែន ដាក់មោឃភាពជាផ្លូវការ** នូវច្បាប់ សន្ធិសញ្ញា កិច្ចព្រមព្រៀង និងឯកសារទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឆ្នាំ១៩៩១ ។

- ទាមទារឲ្យរដ្ឋាភិបាលវៀតណាមរុះរើជំរំ និងតង់យោធា ចេញតំបន់ឈរជើងនៅតាមព្រំដែនកម្ពុជា តាំងពីពាក់កណ្តាលខែមេសា ឆ្នាំ២០២០ ដែលជាការរំលោភច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ក្នុងឯកសារទី២ ស្តីពីបូរណភាពទឹកដីកម្ពុជា និងបំពានគោលការណ៍នៃសមាគម **អាស៊ាន**។

**ខាងក្រោមនេះ ជាកាលបរិច្ឆេទនៃលិខិតបទដ្ឋានរបស់ចលនានិស្សិត ដែលបានចេញផ្សាយ ៖**

- ថ្ងៃទី១២ ខែមិថុនា សេចក្តីថ្លែងការណ៍ ជំរុញឲ្យ«ទាហានវៀតណាម ត្រូវរុះរើជំរំ និងតង់ទាំងអស់ ចេញពីព្រំដែនកម្ពុជា»។

- ថ្ងៃទី១៣ ខែកក្កដា លិខិតចំហជូនលោក **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ដើម្បីបដិសេធចោលសំណើរបស់នាយករដ្ឋមន្ត្រីវៀតណាម ដែលស្នើសុំផ្តល់ឯកសារស្របច្បាប់ ដល់ជនអន្តោប្រវេសន៍វៀតណាមខុសច្បាប់ នៅប្រទេសកម្ពុជា ។

- ថ្ងៃទី១៥ ខែកក្កដា លិខិតចំហ ស្តីពី«វៀតណាមត្រូវតែគោរព និងអនុវត្តតាមច្បាប់អន្តរជាតិ ជាដាច់ខាត» ជូនលោក **ង្វៀន ស្វូនហ៊្វុក** នាយករដ្ឋមន្ត្រីវៀតណាម (July 15, 2020: "Vietnam must firmly respect and comply with the international laws.". The opening letter to **Mr. Nguyen Xuan Phuc**, Prime Minister of the Socialist Republic of Vietnam) ។

- ថ្ងៃទី២១ ខែសីហា សេចក្តីថ្លែងការណ៍ ស្តីពី«ច្រានចោលការបកស្រាយរបស់លោក **ហ៊ុន សែន** លើបញ្ហាបូរណភាពទឹកដី ព្រំដែនគោក ដែនសមុទ្រ កោះត្រល់ និងចង្កោមកោះក្រចកសេះ» ។

- ថ្ងៃទី២៧ ខែសីហា សេចក្តីថ្លែងការណ៍ ស្តីពី«ការបោះតង់ ទៅជាសាងសង់ជម្រករឹងមាំរបស់យោធាវៀតណាម អាចរុញទំនាស់ព្រំដែន ធ្លាក់ក្នុងវិបត្តិធ្ងន់ធ្ងរ» ។

- ថ្ងៃទី១៤ ខែធ្នូ សេចក្តីថ្លែងការណ៍ ស្តីពី«រដ្ឋាភិបាលកម្ពុជា ត្រូវដកខ្លួនចេញពីគម្រោងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម» ។

## ខ). នយោបាយកម្ពុជា

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** បានអំពាវនាវដល់តស្សូរជននយោបាយខ្មែរគ្រប់ភាគី វិលទៅរក **ការផ្សះផ្សា និង ឯកភាពជាតិ** ដើម្បីស្តារស្ថានភាពនយោបាយនៅកម្ពុជា ។

- ថ្ងៃទី១៧ ខែមិថុនា សេចក្តីថ្លែងការណ៍ ស្តីពី «ជំហរឯកភាពជាតិ» ។

## គ). សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** បានធ្វើកិច្ចសហប្រតិបត្តិការល្អ ជាមួយស្ថាប័នជាតិ-អន្តរជាតិ ជាពិសេស ក្រសួងការបរទេស និងសភាសហរដ្ឋអាមេរិក ។

- ថ្ងៃទី២០ ខែមិថុនា តាមប្រព័ន្ធហ្សូម (ZOOM) ថ្នាក់ដឹកនាំចលនានិស្សិត **SMD** បានជួបពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់ នៃក្រសួងការបរទេសអាមេរិក ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ នៅតំបន់អាស៊ី គឺលោក **Christopher Johnson** និងលោកស្រី **Sandra** លើប្រធានបទ ស្តីពី«ការស្តារលិទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្សនៅកម្ពុជា ។

- ថ្ងៃទី០៧ ខែកក្កដា ធ្វើសេចក្តីថ្លែងការណ៍ ស្តីពី«ខួប៤ឆ្នាំ ឃាតកម្មលោកបណ្ឌិត **កែម ឡី**» ស្នើក្រសួងយុត្តិធម៌ បង្ហាញភស្តុតាងតម្លាជាសាធារណៈ និងបើកការស៊ើបអង្កេតឡើងវិញ លើករណីឃាតកម្មលោកបណ្ឌិត **កែម ឡី** ។

- ថ្ងៃទី០៩ ខែកក្កដា ធ្វើសេចក្តីបំភ្លឺទៅលោក **ជិន ម៉ាលីន** អ្នកនាំពាក្យក្រសួងយុត្តិធម៌ ជុំវិញសេចក្តីថ្លែងការណ៍ របស់ចលនានិស្សិត **SMD** ក្នុងខួប៤ឆ្នាំ នៃឃាតកម្មបណ្ឌិត **កែម ឡី**» ដោយបំភ្លឺបញ្ជាក់ថា «ចលនានិស្សិត **SMD** ពុំមែនធ្វើអាជីវកម្មនយោបាយ ដូចការពោលរបស់លោក **ជិន ម៉ាលីន** ទេ» ។

- ថ្ងៃទី០៨ ខែកញ្ញា ធ្វើលិខិតផ្ញើជូនសមាជិកព្រឹទ្ធសភាអាមេរិក លោក **លីនសី គ្រាហាំ (Linsey Graham)** «បេះដូងពលរដ្ឋខ្មែរ មើលឃើញថា សហរដ្ឋអាមេរិក ជាអ្នករំដោះ" (September 8, 2020, letter to Senator Linsey Graham "Cambodian people's hearts see the United State of America as a liberator" ។ ថ្ងៃទី០៨នេះ យើងខ្ញុំក៏បានផ្ញើលិខិតស្រដៀងគ្នានឹងលិខិតខាងលើ ទៅកាន់សមាជិករដ្ឋសភាអាមេរិក លោក **អាឡិន ឡូវិនថល (Allen Lowenthal)** និងផ្ញើជូនរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក លោក **ម៉ៃ ផុមពីអូ (Mike Pompeo)** ។ ខ្លឹមសារនៃលិខិតទាំងនេះ ស្នើដល់

សហរដ្ឋអាមេរិក ជម្រុញអាជ្ញាធរកម្ពុជា ឲ្យដោះលែងអ្នកទោសមនសិការទាំងអស់ ព្រមទាំងសកម្មជននយោបាយ សិទ្ធិមនុស្ស បរិស្ថាន និងសកម្មជនព្រំដែន ។

- ថ្ងៃទី២៨ ខែកញ្ញា ផ្ញើញត្តិជូនរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក «ពលរដ្ឋខ្មែរមានក្តីសង្ឃឹមថ្មី និង មិនឯកការ ដោយការយកចិត្តទុកដាក់របស់សហរដ្ឋអាមេរិក ពីសម្លេងសុំអន្តរាគមន៍របស់ពលរដ្ឋខ្មែរ (September 28, 2020, Petition to the US Secretary Of State "Cambodian people have new hope and not alone)» ។
- ថ្ងៃទី២៨ ខែកញ្ញា ផ្ញើ «ញត្តិជូនរដ្ឋាភិបាលកម្ពុជា» ស្នើឲ្យមានការដោះលែងអ្នកទោសមនសិការ និងអ្នកទោសនយោបាយទាំងអស់ តាមរយៈលោក **ជុំ សុន្ទរី** ឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ។
- ថ្ងៃទី២៦ ខែវិច្ឆិកា ជំរុញ«តុលាការកម្ពុជា ត្រូវទម្លាក់ចោលបទចោទលើក្រុមសកម្មជន» គឺត្រូវដោះលែងអ្នកទោសមនសិការទាំងអស់ ដោយឥតលក្ខខណ្ឌ ។
- ថ្ងៃទី១០ ខែធ្នូ ធ្វើសេចក្តីថ្លែងការណ៍ «អបអរទិវាសិទ្ធិមនុស្សអន្តរជាតិថ្ងៃទី១០ ធ្នូ គម្រប់ខួបលើកទី៧២ឆ្នាំ» ស្តីពីការជំរុញរដ្ឋាភិបាលលោក **ហ៊ុន សែន** ឲ្យដោះលែងអ្នកទោសមនសិការ ដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា។
- ថ្ងៃទី១៤ ខែធ្នូ ជំរុញ«រដ្ឋាភិបាលកម្ពុជា ត្រូវដកខ្លួនចេញពីគម្រោងតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ និង វៀតណាម» ដើម្បីបញ្ចៀសហានិភ័យធ្ងន់ធ្ងរ ដល់ប្រទេសជាតិខ្មែរ នៅថ្ងៃអនាគត។

## ៣. លទ្ធផលការងារ និងទិសដៅបន្ត

រាល់សេចក្តីថ្លែងការណ៍ និងសារលិខិតរបស់ **ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** បានទទួលការឆ្លើយតប និងគាំទ្រយ៉ាងទំហឹងអំពីស្ថាប័នជាតិ និងអន្តរជាតិ ជាពិសេស ពីក្រសួងការបរទេសសហរដ្ឋអាមេរិក ។ ដោយឡែក រដ្ឋាភិបាលលោក **ហ៊ុន សែន** មិនបានឆ្លើយតបជាផ្លូវការ ដល់ការស្នើសុំរបស់**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ឡើយ ។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ប្តេជ្ញាបន្តបេសកកម្មឆ្នាំថ្មី ២០២១ ដើម្បី«**ស្វែងរកឯកភាពជាតិ និងសន្តិភាពថ្លៃថ្នូរ, ពង្រឹងការគោរពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ, ការពារទឹកដីព្រំដែន និងដោះស្រាយបញ្ហាអន្តោប្រវេសន៍ខុសច្បាប់, ជម្រុញគោលដៅយុត្តិធម៌សង្គម និង នីតិរដ្ឋស្អាតស្អំ**» ជូនប្រជាពលរដ្ឋខ្មែរទូទៅ ។

យើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងសកម្មជននៃ**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ព្រមទាំងបងប្អូនខ្មែរ និងមិត្តភក្តិអន្តរជាតិទាំងឡាយ ដែលបាននិងបន្តគាំទ្រយើងខ្ញុំ ។

រដ្ឋធានីវ៉ាស៊ីនតោន ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២១

**អ្នកធ្វើរបាយការណ៍**

**អនុប្រធានប្រតិបត្តិ**

**គិម សេង**


**<u>ទំនាក់ទំនង ៖</u>**

*2402 24th St SE Washington, DC 20020*

*t*: (570) 899 7597
*e*: smd2khmer@gmail.com
*w*: www.cambodiademocracy.org
*p*: https://www.facebook.com/cambodiademocracy.org
*y*: https://www.youtube.com/user/Kimsengkhus